Australian Government
Department of Human Services

# តើលោកអ្នកមានកូនដល់អាយុៈបួនឆ្នាំនៅក្នុងឆ្នាំហិរញ្ញវត្ថុនេះទេ?

## ប្រសិនបើមាន សូមកុំភ្លេចធ្វើការពិនិត្យសុខភាព ។

ប្រសិនបើគ្រួសាររបស់លោអ្នកទទួលបាន Family Tax Benefit Part A
និងការបង់ប្រាក់ឧបត្ថម្ភចំណូលដូចជាៈ

- Parenting Payment,
- Newstart Allowance, **ឬ**
- ពី Department of Veterans' Affairs

កូនរបស់លោកអ្នកនឹងត្រូវធ្វើការពិនិត្យសុខភាពដើម្បីឲ្យលោកអ្នកទទួលបាន Family Tax Benefit Part A Supplement។

## ការពិនិត្យសុខភាព

ការពិនិត្យសុខភាពគឺជាការវាយតម្លៃសុខភាពរាងកាយកូនរបស់លោកអ្នក និងសុខមាលភាពទូទៅ។ ការពិនិត្យសុខភាពរួមមាន ការពិនិត្យកំពស់ ទំងន់ ការពិនិត្យមើលសោតវិញ្ញាណ (ត្រចៀក) និងចក្ខុវិស័យ (ភ្នែក) ។ ការពិនិត្យសុខភាពធានានាថាកូនរបស់លោកអ្នកមានសុខភាពល្អ មានរូបរាងសមរម្យ និងត្រៀមខ្លួនរួចរាល់ដើម្បីសិក្សានៅពេលដែលពួកគេចាប់ផ្ដើមទៅសាលារៀន។ ការពិនិត្យសុខភាពអាចត្រូវធ្វើនៅពេលណាមួយចាប់ពីកូនរបស់លោកអ្នកចូលដល់អាយុៈបីឆ្នាំ។

## តើលោកអ្នកត្រូវធ្វើអ្វីខ្លះ

**ការរៀបចំចាត់ចែងធ្វើការពិនិត្យសុខភាពកូនរបស់លោកអ្នក។** ការពិនិត្យសុខភាពអាចជា Healthy Kids Check, ការពិនិត្យសុខភាពទៅលើភាពសមរម្យនៃអាយុៈ ឬអ្វីមួយដែលស្រដៀងគ្នានេះ។ ដើម្បីទទួលបានការពិនិត្យ សុខភាពសំរាប់កូនរបស់លោកអ្នក លោកអ្នកអាចៈ

- ទស្សនាគ្លីនិចសុខភាពមាតា និងកុមារ នៅតាមរដ្ឋ ឬដែនដី **ឬ**
- ជួបជាមួយវេជ្ជបណ្ឌិត ឬគិលានុប្បដ្ឋាយិការនៅមូលដ្ឋានរបស់លោកអ្នក

សំរាប់ពត៌មានច្រើនថែមទៀតស្តីពីការពិនិត្យសុខភាព សូមនិយាយទៅកាន់អ្នកជំនាញសុខភាព ឬ គ្លីនិចសុខភាពរបស់លោកអ្នក។

**ត្រូវប្រាប់យើងអំពីការពិនិត្យសុខភាពដែលបានធ្វើហើយ។** ការធ្វើដូចនេះគឺដើម្បីធានាឲ្យលោអ្នកទទួលបាន Family Tax Benefit Part A Supplement រហូតដល់$ 726.35 ក្នុងកូនម្នាក់ដែលមានសិទ្ធិទទួល។ របៀបដែលងាយស្រួលបំផុតដើម្បីប្រាប់យើងគឺការប្រើប្រាស់ Online Services. ។ ដើម្បីធ្វើរឿងនេះ សូមទស្សនា **humanservices.gov.au/onlineservices**

# ហេតុអ្វីបានជាលោកអ្នកត្រូវប្រាប់យើង

នៅចុងឆ្នាំហិរញ្ញវត្ថុ យើងធ្វើតុល្យការនៃការបង់ប្រាក់របស់លោកអ្នក។. ដូច្នេះ ប្រសិនបើការពិនិត្យសុខភាព មិនបានធ្វើទេ ឬ លោកអ្នកមិនបានប្រាប់យើងមុន ថ្ងៃ 30 មិថុនា នោះប្រាក់ទាំងអស់ ឬប្រាក់មួយផ្នែកនៃ Family Tax Benefit Part A Supplement សំរាប់កូនរបស់លោកអ្នកនឹងត្រូវដកទុក។

ប្រសិនបើមានហេតុផលណាមួយដែលមិនអាចធ្វើបានក្នុងការពិនិត្យសុខភាពកូនរបស់លោកអ្នក លោកអ្នកត្រូវប្រាប់យើងឲ្យបានលឿនដែលអាចធ្វើទៅបាន។

## សំរាប់ពត៌មានច្រើនថែមទៀត

- ទស្សនា **humanservices.gov.au**
- ហៅទៅខ្សែទូរស័ព្ទសំរាប់គ្រួសារ និងឪពុកម្តាយរបស់យើងតាមលេខ **136 150**
- ហៅទៅលេខ **131 202** សំរាប់ពត៌មានជាភាសាផ្សេងៗក្រៅពីភាសាអង់គ្លេស
- ទស្សនា DHS Service Centre នៅតាមមូលដ្ឋានរបស់លោកអ្នក និង និយាយទៅកាន់ Customer Service Officer ។

# សិទ្ធិបដិសេធ

ព័ត៌មាននេះត្រឹមត្រូវនៅខែ ឧសភា 2012។ ប្រសិនបើលោកអ្នកប្រើប្រាស់នូវការបោះពុម្ពផ្សាយនេះក្រោយកាលបរិច្ឆេទនោះ
សូមពិនិត្យមើលជាមួយនឹងយើងដើម្បីដឹងថាសេចក្តីពិស្តារនោះមានលក្ខណៈបច្ចុប្បន្នភាព។

នៅថ្ងៃ 1 កក្កដា 2011 Family Assistance Office, Medicare Australia, Centrelink, Child Support Agency និង CRS Australia បានក្លាយទៅជា Australian Government Department of Human Services។ ឥឡូវនេះក្រសួងនេះផ្តល់នូវការបង់ប្រាក់ និងសេវានានារបស់ពួកគេ។ លោកអ្នកនឹងឃើញការផ្លាស់ប្តូរ ចំពោះផ្លាកសញ្ញា គេហៈទំព័រ សារទូរស័ព្ទ ឯកសារយោង និងនិមិត្តសញ្ញានានា នៅលើលិខិតទំនាក់ទំនង របស់យើង ដូចដែលយើងផ្លាស់ប្តូរទៅជាក្រសួងថ្មី។ សូមសិក្សាស្វែងយល់ច្រើនថែមទៀតនៅឯ **humanservices.gov.au**

# Do you have a child turning four in this financial year?

## If so, don't forget to get a health check.

If your family receives Family Tax Benefit Part A and an income support payment such as:

- Parenting Payment,
- Newstart Allowance, **or**
- from the Department of Veterans' Affairs

your child will need to have a health check for you to receive the Family Tax Benefit Part A Supplement.

## Health check

A health check is an assessment of your child's physical health and general wellbeing. It includes height, weight, hearing and sight checks. It ensures your child is healthy, fit and ready to learn when they start school. It can be done anytime from when your child turns three.

## What you need to do

**Arrange a health check for your child.** The health check could be a Healthy Kids Check, an age-appropriate health check or something similar. To get a health check for your child, you can:

- visit a State or Territory child and maternal health clinic, **or**
- visit your local doctor or practice nurse.

For more information about health checks, please talk to your health professional or health clinic.

**Tell us the health check has been completed.** This is to ensure you receive the Family Tax Benefit Part A Supplement of up to $726.35 per eligible child. The easiest way to tell us is by using Online Services. To do this, visit **humanservices.gov.au/onlineservices**

## Why you need to tell us

At the end of the financial year we balance your payment. So, if the health check isn't done or you haven't told us before 30 June, part or all of the Family Tax Benefit Part A Supplement for your child will be withheld.

If there's a reason a health check can't be completed for your child, you should tell us as soon as possible.

## For more information

- Visit **humanservices.gov.au**
- Call our parents and families line on **136 150**
- Call **131 202** for information in languages other than English
- Visit your local DHS Service Centre and talk to a Customer Service Officer.

## Disclaimer

This information is accurate as at May 2012. If you use this publication after that date, please check with us that the details are current.

On 1 July 2011, the Family Assistance Office, Medicare Australia, Centrelink, Child Support Agency and CRS Australia became the Australian Government Department of Human Services. The department now provides their payments and services. You will see changes to our signage, websites, phone messages, references and logos on our correspondence, as we change over to the new department. Learn more at **humanservices.gov.au**



FPR080.1206